# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ The Asian International Justice Initiative**

**ឆ្នាំទី១ លេខ ១៧** **សប្តាហ៍ទី១៧ (១៧- ២០ សីហា ឆ្នាំ២០០៩)**


## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



*រូបភាព : លោក Robert Hamill ដើមបណ្តឹងរដ្ឋប្បវេណី និង លោក **អ៊ូ សាវិទ្ធ** ផ្តល់សក្ខីកម្មពីចំងាយតាមរយៈប្រព័ន្ធ Video-conference ពីប្រទេសបារាំង*

## ១. សេចក្តីសង្ខេប

"ខ្ញុំមកនេះមិនធ្វើការសងសឹកទេ ខ្ញុំមកដើម្បីស្វែងរកការពិត ប៉ុន្តែបើជនជាប់ចោទមិនឆ្លើយការពិត ខ្ញុំនឹងមិនអភ័យទោសឱ្យទេ"[1] ។

នៅសប្តាហ៍ទី១៧នេះ ការកំណត់ពេលស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីត្រូវលើកឡើង គឺមានចំនួនពីរសប្តាហ៍ ។ នាសប្តាហ៍នេះ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣រូប បានថ្លែងរៀបរាប់អំពីទុក្ខសោករបស់ខ្លួន ដែលបាត់បង់មនុស្សជាទីស្រលាញ់នៅមន្ទីរ ស-២១ ដោយថ្លែងពីបទពិសោធន៍សោកសៅចំពោះមរណភាពសមាជិកគ្រួសារខ្លួន ។ ជាលទ្ធផល ការប៉ះទង្គិចផ្លូវចិត្តត្រូវបានកើតឡើងកាន់តែខ្លាំងឡើង ដោយសារតែដឹងថាមនុស្សជាទីស្រឡាញ់របស់ខ្លួនដែលត្រូវបានឃុំខ្លួននៅមន្ទីរ ស-២១នោះ អាចត្រូវបានរងការប្រព្រឹត្តដោយអមនុស្សធម៌ រងទារុណកម្មដ៏ឃោរឃៅ និងសម្លាប់យ៉ាងព្រៃផ្សៃ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នាពីការបាត់បង់ព័ត៌មាន និងឯកសារពាក់ព័ន្ធនានានឹងសមាជិកគ្រួសារខ្លួន ។ បន្ថែមពីលើនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានតាំងសំណួរទៅកាន់ជនជាប់ចោទសាកសួរពីមនុស្សជាទីស្រលាញ់ តើត្រូវទទួលរងទារុណកម្ម និងសម្លាប់ដោយរបៀបណា? សាកសពកប់នៅទីណា? ជាការឆ្លើយតប ទោះយ៉ាងណា ជនជាប់ចោទនៅតែប្រកាន់ជំហរថា គាត់មិនសូវដឹងពីវាសនារបស់អ្នកទោសម្នាក់ៗទេ ។

[1] សេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ភីង ហុតស៊ុនថារី នាសវនាការ នៅថ្ងៃពុធ ទី២១ សីហា ២០០៩ ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សេចក្តីសង្ខេបសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី

អនុលោមទៅតាមកាលវិភាគ អង្គជំនុំជម្រះបានស្តាប់សេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣រូប នាសប្តាហ៍នេះ ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានខិតខំស្វះស្វែងបង្ហាញឯកសារភស្តុតាងសំខាន់ៗ ដើម្បីគាំទ្រការអះអាងកូនក្តីរបស់ខ្លួន ។ នៅទីបញ្ចប់ មេធាវីការពារក្តីបានធ្វើការសង្កេតថា ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២រូប ពុំមានឯកសារគាំទ្រជាមូលដ្ឋានចំពោះពាក្យស្នើសុំ ។ ចំពោះការទាមទារសំណងវិញ ដើមបណ្តឹងរដ្ឋប្បវេណីបានទុកសិទ្ធិទាមទារនេះដល់មេធាវីរបស់ខ្លួន ។

ផ្អែកតាមវិធាន ២៣(១) នៃវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញពីភាពឈឺចាប់ផ្លូវកាយ និងផ្លូវចិត្ត ដែលរងផលប៉ះពាល់ ដោយផ្ទាល់ ឬដោយប្រយោល ដែលជនជាប់ចោទត្រូវទទួលខុសត្រូវលើទង្វើទាំងនោះ ។ ចុងបញ្ចប់នៃសេចក្តីថ្លែងការណ៍ ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញពីភាពឈឺចាប់ និងការបាត់បង់សមាជិកគ្រួសារ ដែលបង្ហាញពីការស៊ូទ្រាំរស់នៅដោយក្តីទុក្ខព្រួយ និងបង្កើតជាផលអាក្រក់វែងឆ្ងាយក្នុងជីវិតគ្រួសាររបស់គាត់ ។ ជាការពិត ការរំជួលចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញយ៉ាងជ្រាលជ្រៅកំឡុងកិច្ចដំណើការសវនាការរយៈពេល ៤ថ្ងៃនេះ ដោយរំលឹកនូវការចងចាំមនុស្សជាទីស្រលាញ់ត្រូវស្លាប់នៅមន្ទីរ ស-២១ ។ បន្ថែមពីលើនេះ ពួកគេបានរៀបរាប់ពីគុណសម្បត្តិ និងគុណតម្លៃរបស់ជនរងគ្រោះនៅក្នុងគ្រួសារ ព្រមទាំងការរងរបួសផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ នៅពេលទទួលដំណឹងពីការស្លាប់នេះ ដែលជាហេតុនាំឱ្យទាមទារសំណងជំងឺចិត្តលើការបាត់បង់មនុស្សជាទីស្រឡាញ់ និងជាបង្គោលរកស៊ីចញ្ចឹមគ្រួសារ ។

***ខាងក្រោមនេះ ជាដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីថ្លែងការណ៍ នាសប្តាហ៍នេះ :***

- លោកស្រី **Martine Lefèvre** និងលោកស្រី **អ៊ុក នារី** ជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ។ លោកស្រី **Martine Lefèvre** ត្រូវជាប្រពន្ធ និងលោកស្រី **អ៊ុក នារី** ត្រូវជាកូនរបស់លោក **អ៊ុក កេត** ដែលបានជាប់ឃុំ និង សម្លាប់នៅមន្ទីរ ស-២១ ។
- លោក **Robert Hamill** ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ។ លោក **Robert Hamill** បានដាក់ពាក្យបណ្តឹងដោយហេតុថា បងប្រុសរបស់គាត់ **Kerry Hamill** ត្រូវជាប់ឃុំឃាំង និងសម្លាប់នៅមន្ទីរ ស-២១ ។
- លោកស្រី **Antonia Tiulong** ដើមបណ្តឹងរដ្ឋប្បណើក្រុម ២ ។ លោកស្រី បានតំណាងឱ្យម្តាយ បងស្រី ក្មួយស្រី និង ក្មួយប្រុស ដែលបានដាក់ពាក្យបណ្តឹងដោយឡែកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ពាក្យបណ្តឹងធ្វើឡើងដោយហេតុ ថា លោកស្រី **Rainsy Tiulong** និងប្តី **លឹម គីម៉ារី** ដែលត្រូវជាបងរបស់លោកស្រីត្រូវស្លាប់នៅមន្ទីរ ស-២១ ។
- លោកស្រី **ហាវ សុភា** ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ជាជាតិខ្មែរ បានធ្វើការប្តឹងថា បានបាត់បង់ឪពុកឈ្មោះ **ហាវ ស៊ា** ហៅ **ហាវ ហាន** នៅមន្ទីរ ស-២១ ។

- លោកស្រី **សូ សួង** ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ។ បងថ្លៃប្រុសលោកស្រី ឈ្មោះ **មាស ស៊ុន** ត្រូវបានឃុំឃាំង និងកំទេចនៅ មន្ទីរ ស-២១ ។
- លោក **នេត ផល្លី** ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ។ លោក **នេត ផល្លី បាន**បាត់បង់បងប្រុសខ្លួន ឈ្មោះ **នេត ប៊ុនធី** នៅមន្ទីរ ស-២១ ។
- លោកស្រី **អ៊ឹម ស៊ុទ្ធី** និងលោក **ភឹង ហ្គុតស៊ុនថារី** ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ។ លោកស្រី **អ៊ឹម ស៊ុទ្ធី** និង **ភឹង ហ្គុតស៊ុនថារី** ត្រូវជាភរិយា និងកូនស្រីរបស់លោកសាស្ត្រាចារ្យ **ភឹង តុន** ។ លោកសាស្ត្រាចារ្យ **ភឹង តុន** គឺជាសាស្ត្រាចារ្យច្បាប់ជាន់ខ្ពស់ម្នាក់ និងជាអតីតព្រឹទ្ធបុរសមហាវិទ្យាល័យភ្នំពេញ និងត្រូវបានជាប់ឃុំ និងកំទេចនៅមន្ទីរ ស-២១។
- លោក **សៀង វណ្ណី** ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ។ លោក **សៀង វណ្ណី** បានបាត់បង់ប្អូនប្រុស ២នាក់ គឺ **សៀង ផុន** និង **សៀង ផាត** កំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចម្លើយសារភាពរបស់ **សៀង ផុន** បានរកឃើញនៅមន្ទីរ ស-២១ ប៉ុន្តែវាសនារបស់ **សៀង ផាត** មិនទាន់ដឹងនៅឡើយទេ ។
- លោក **ជុំ ស៊ីរ៉ាត់** ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ។ លោក **ជុំ ស៊ីរ៉ាត** បានដាក់ពាក្យបណ្តឹងអំពីការបាត់ប្អូនប្រុសឈ្មោះ **ជុំ ណារិទ្ធ** ព្រមទាំងភរិយា **គីម សុវណ្ណារី** និងកូនក្នុងផ្ទៃ និង **ជុំ ស៊ីណារ៉េត** ។
- លោកស្រី **ជុំ នៅ** ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ ។ លោកស្រី **ជុំ នៅ** បានដាក់ពាក្យបណ្តឹងក្នុងនាមខ្លួនលោកស្រីផ្ទាល់ ព្រមទាំងជំនួសកូនស្លាប់នៅព្រៃស និងប្តីត្រូវពិឃាដនៅមន្ទីរ ស-២១ ។ នៅថ្ងៃព្រហស្បតិ៍ ដំណើរការសវនាការត្រូវបាន ផ្អាកមុនបញ្ចប់សក្ខីកម្មរបស់គាត់ ហើយដំណើររឿងនេះនឹងផ្តល់ជូននៅក្នុងរបាយការណ៍បន្ទាប់ ។
- លោក **អ៊ូ សាវិរិទ្ធ** ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ ។ លោក **អ៊ូ សាវិរិទ្ធ** បានផ្តល់សក្ខីកម្មពីប្រទេសបារាំងតាមប្រព័ន្ធវីឌីអូ ដែលជាព្រឹត្តិការណ៍ដំបូងចំពោះការការស្តាប់សក្ខីកម្មពីចម្ងាយក្នុងដំណើរការនីតិវិធី ។ ប្អូនប្រុសរបស់លោកឈ្មោះ **អ៊ូ វណ្ណី** បានជាប់ឃុំ និងកំទេចនៅមន្ទីរ ស-២១ ។

## ខ. អំណះអំណាង និងកង្វល់លើកឡើងនៅពេលសវនាការ

***ការលើកកម្ពស់សិទ្ធិជនជាប់ចោទកំឡុងសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី :*** អង្គជំនុំជម្រះបានយកចិត្តទុកដាក់គួរឱ្យកោតសរសើរដើម្បីធានាពីសិទ្ធិជនជាប់ចោទមិនត្រូវរំលោភបំពាន ខណៈពេលដែល *ដើមបណ្តឹងរដ្ឋប្បវេណី* បានតាំងសំណួរ និងប្រើពាក្យស្តីបន្ទោសធ្ងន់ៗចំពោះជនជាប់ចោទ ។ ថ្វីបើអង្គជំនុំជម្រះអនុញ្ញាតឱ្យ *ដើមបណ្តឹងរដ្ឋប្បវេណី* តាំងសំណួរដល់ជនជាប់ចោទ ក៏គាត់បានដាស់តឿនជាញឹកញាប់ដល់ជនជាប់ចោទពីសិទ្ធិនៅស្ងៀមមិនឆ្លើយ ។ ខណៈដែល *ដើមបណ្តឹងរដ្ឋប្បវេណី* ប្រើពាក្យសំដីធ្ងន់ៗ ដោយចេតនា ដើម្បីឱ្យធូរស្បើយអារម្មណ៍រំជួលចិត្តខ្លួន ប្រធានអង្គជំនុំជម្រះបានដាស់តឿនភ្លាមៗពី *"ការប្រើពាក្យមិនសមរម្យ និងគ្មានសីលធម៌"* នៅសវនាការសាធារណៈ ។ វិធានការនេះ រក្សាតុល្យភាពរវាងការអនុវត្តន៍សិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិជនជាប់ចោទ ដែល *សន្មតថាគ្មានទោស* ។ ដូច្នេះ សេចក្តីថ្លៃថ្នូរនៅកិច្ចដំណើរការនីតិវិធីត្រូវធានាឱ្យបានមុតមាំ ។

## ៣. ការចូលរួម និងការគាំពារសាក្សី និងជនរងគ្រោះ

***វត្តមានដើមបណ្តឹងរដ្ឋប្បវេណី :*** នាសប្តាហ៍នេះ វត្តមានដើមបណ្តឹងរដ្ឋប្បវេណីកើនឡើងគួរសម ទោះជាចំនួននេះបានថយចុះបន្តិចនៅថ្ងៃបន្តបន្ទាប់ ។ នៅថ្ងៃច័ន្ទ វត្តមានភាគីដើមបណ្តឹងមានចំនួន ១០រូប ថ្ងៃអង្គារ ១១រូប និងថ្ងៃពុធ ៨រូប និងថ្ងៃព្រហស្បតិ៍ ៧រូប ។

***ការណែនាំថ្មីចំពោះការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី :*** ដោយសារសប្តាហ៍នេះ ជាការចាប់ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញពីភាពសមស្របនូវសេចក្តីណែនាំកាលពីថ្ងៃទី៥ ខែសីហា ២០០៩ ដែលអង្គជំនុំជម្រះបានផ្ទេរការទទួលខុសត្រូវដឹកនាំការសាកសួរដើមបណ្តឹងរដ្ឋប្បវេណីដល់មេធាវីតាមក្រុមតំណាង ។ គួរឱ្យកត់សម្គាល់ជាពិសេសថា គឺជាការទទួលខុសត្រូវរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីធានាថា កូនក្តីខ្លួនមិនផ្តល់សក្ខីកម្មដែលមិនពាក់ព័ន្ធ ឬប្រាសចាកពីប្រធានបទ ។ អង្គជំនុំជម្រះក៏បានបញ្ជាក់ច្បាស់ថា ដោយមូលហេតុនេះហើយ ដែលខ្លួនមិនជ្រៀតជ្រែកក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី លើកលែងតែករណីចាំបាច់ធានាថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មានឱកាសផ្តល់សក្ខីកម្មខ្លួន និងការតាំងសំណួរមិនប្រាសចាកពីប្រធានបទ ឬប្រើពេលលើសម៉ោងកំណត់ ។ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីអានសេចក្តីថ្លែងការណ៍ខ្លួន ។

គោរពតាមសេចក្តីណែនាំ ភាគីនានានៃនីតិវិធីមានឱកាសធ្វើការសង្កេតលើសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់ការសួរដេញដោលរបស់ខ្លួន ។ អង្គជំនុំជម្រះរក្សាសិទ្ធិសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើមានករណីចាំបាច់ ។ ការលើកឡើងពីម៉ោងពេលត្រូវការ អង្គជំនុំជម្រះបានថ្លែងថា ១/៣ នៃម៉ោងកំណត់ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មគួរត្រូវប្រើក្នុងការថ្លែងការណ៍ ។

***ការដាក់សំណើជំទាស់បឋមលើពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី :*** ការចង្អុលបង្ហាញដោយអង្គជំនុំជម្រះកាលពីសប្តាហ៍មុននៅថ្ងៃច័ន្ទ បានកំណត់ឱ្យមេធាវីការពារក្តីដាក់សេចក្តីសន្និដ្ឋានជំទាស់បឋមលើពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីការពារក្តីអន្តរជាតិលោកស្រី **Canizares** បានលើកឡើងថា ពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៩ច្បាប់ មានបញ្ហា ។ ការជំទាស់នេះបង្កើតជាគោលការណ៍ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានឯកសារគ្រប់គ្រាន់ក្នុងការបង្ហាញពីចំណងញាតិលោហិតជាមួយជនរងគ្រោះនៅមន្ទីរ ស-២១ ។ ទោះបីជាយ៉ាងណា ការជំទាស់របស់មេធាវីការពារក្តីអាចដកវិញបាន ប្រសិនបើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្តល់នូវឯកសារគ្រប់គ្រាន់ក្នុងការទាមទាររបស់កូនក្តីខ្លួន ។ ការពិភាក្សាលើការជំទាស់នេះ និងកាលបរិច្ឆេទបញ្ចប់ការដាក់ឯកសារផ្សេងៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងលើកឡើង បន្ទាប់ពីភាគីបញ្ចប់ការដាក់សេចក្តីសន្និដ្ឋានខ្លួន ។

***ការផ្តល់អ្នកជំនាញផ្លូវចិត្តដល់ជនរងគ្រោះ :*** អង្គជំនុំជម្រះបានយកចិត្តទុកដាក់លើដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តល់អ្នកជំនាញខាងចិត្តសាស្ត្រជាជំនួយ ។ មន្ត្រីជំនាញខាងចិត្តសាស្ត្រពីអង្គការ TPO បានផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី **អ៊ុំ ស៊ុន្ទី** និង **ជុំ នៅ** នៅពេលពួកគាត់រំជួលចិត្តខ្លាំង កំឡុងពេលផ្តល់សក្ខីកម្ម ។

***សិទ្ធិទទួលបានតំណាងសមស្របរបស់ដើមបណ្តឹងរដ្ឋប្បវេណី :*** មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិក្រុម២ និងក្រុម៤ លោក **គង់ ពិសី** អវត្តមាន នាសប្តាហ៍នេះ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិក្រុម៤ លោក **ហុង គីមសួន** អវត្តមានចំនួនបីថ្ងៃដំបូងនៃកិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ ទោះបីជាយ៉ាងណា គាត់បានមានវត្តមាន នៅពេលកូនក្តីខ្លួនឡើងធ្វើសេចក្តីថ្លែងការណ៍ចំពោះអង្គ ជំនុំជម្រះនៅថ្ងៃព្រហស្បតិ៍ ។

***ការត្រៀមរៀបចំលក្ខណៈ :*** ជាទូទៅ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញពីការរៀបចំមួយដ៏ប្រសើរក្នុងការផ្តល់ឯកសារភស្តុតាង ដើម្បីគាំទ្រលើការទាមទាររបស់កូនក្តីខ្លួន ។ ផ្ទុយទៅវិញ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ លោក **ហុង គីមសួន** មិនបានត្រៀមលក្ខណៈឱ្យបានល្អទេនាសប្តាហ៍នេះ ខណៈពេលកូនក្តីខ្លួនផ្តល់សក្ខីកម្ម ។ គាត់បានបង្ហាញឯកសារអះអាងដល់អង្គជំនុំជម្រះដែលឯកសារនោះមិនទាន់បានដាក់បញ្ចូលក្នុងសំណុំរឿងធ្វើឱ្យមេធាវីការពារក្តីគ្មានឱកាសសិក្សាលើឯកសារនោះ ។ ជាងនេះទៀត នៅពេលសាកសួរអំពីប្រភពឯកសារ ជាពិសេស រូបថតបងប្រុសរបស់កូនក្តីខ្លួន ដែលអះអាងថាបានមកពីមន្ទីរ ស-២១ លោក **ហុង គីមសួន** មិនអាចផ្តល់នូវព័ត៌មានពីប្រភពឯកសារនោះឡើយ ។ បញ្ហានេះបញ្ជាក់ពីកង្វះការត្រៀមរៀបចំលក្ខណៈជាមុនរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

***ការកែប្រែកាលវិភាគសវនាការលើការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី :*** កិច្ចខិតខំប្រឹងប្រែងជំរុញនីតិវិធីឱ្យរលូន និងការទទួលបានការស្នើសុំដកដើមបណ្តឹងរដ្ឋប្បវេណីមិនចូលធ្វើសេចក្តីថ្លែងចំពោះមុខអង្គជំនុំជម្រះ នៅថ្ងៃអង្គារ អង្គជំនុំជម្រះបានប្រកាសកាលវិភាគថ្មីសម្រាប់សប្តាហ៍នេះ ។ ខណៈដែលថ្ងៃពុធ សវនាការបានប្រព្រឹត្តធម្មតា តាមកាលវិភាគ លោកស្រី **ឈិន ណាវី** មិនអាចផ្តល់សក្ខីកម្មបានទេ នៅថ្ងៃព្រហស្បតិ៍ ដោយសារបញ្ហាសុខភាព ។ ដូច្នេះ កម្មវិធី ត្រូវបានជំនួសដោយ សេចក្តីថ្លែងការណ៍របស់លោកស្រី **ជុំ នៅ** ។

***កង្វះការប៉ាន់ប្រមាណពេលវេលាសម្រាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី :*** សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី **ជុំ នៅ** មិនត្រឹមតែលើកពេលទេ ថែមទាំងបង្អាក់ពីរលើកថែមទៀត ។ នៅពេលបញ្ចប់ការស្តាប់សក្ខីកម្មលោក **ជុំ ស៊ីរ៉ាត់** លោកស្រី **ជុំ នៅ** បានចាប់ផ្តើមសេចក្តីថ្លែងខ្លួនប្រហែលជា ២០នាទី ត្រូវបញ្ឈប់សម្រាប់អាហារថ្ងៃត្រង់ និងបង្អាក់ម្តងទៀត ដោយសារកម្មវិធីស្តាប់សក្ខីកម្ម លោក **អ៊ូ សាវិទ្ធិ** តាមប្រព័ន្ធឆ្លើយឆ្លងពីចំងាយ ។ នៅពេលសក្ខីកម្មរបស់លោក **អ៊ូ សាវិទ្ធិ** ត្រូវបញ្ចប់ លោកស្រីផ្តល់សក្ខីកម្មបន្ត តែដោយសារបញ្ហាប្រព័ន្ធបច្ចេកទេស ប្រព័ន្ធសម្លេងមិនដំណើរការ សក្ខីកម្មលោកស្រីត្រូវលើកទៅធ្វើនៅថ្ងៃក្រោយ ។ ចំពោះបញ្ហាបច្ចេកទេស យើងមិនអាចសន្និដ្ឋានជាមុន ប៉ុន្តែគួរអាចបញ្ចៀសបាននូវការបង្អាក់ខានលើកទីមួយ ដោយសារកម្មវិធីស្តាប់សក្ខីកម្មពីចំងាយ (video-conference) ត្រូវបានរៀបចំជាមុន ឬ គួរបង្ហាញហេតុផលពីគោលបំណងចង់ប្រើប្រាស់ពេលវេលានៅសល់ដើម្បីពន្លឿន កិច្ចដំណើរការនីតិវិធី ។

## ៤. ការគ្រប់គ្រងសវនាការ

***ការចូលរួមរបស់ភាគី :*** នាសប្តាហ៍នេះ លោក **សេង ប៊ុនឃាង** តំណាងឱ្យសហព្រះរាជអាជ្ញាជាតិ និងលោក **Vincent de Wilde** តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។ លោក **ការ សាវុត្ថ** និង អ្នកស្រី **Canizares** **មាន**វត្តមានតំណាងសហមេធាវីការពារក្តី ។

***ការចូលរួមពីសាធារណៈជន :*** នៅថ្ងៃច័ន្ទ សហគមន៍ខ្មែរ-ឥស្លាម ប្រមាណជា ៥០០នាក់ បានចូលរួមសវនាការ ដែលជាចំនួនតួលេខខ្ពស់បំផុតចាប់តាំងពីការចាប់ផ្តើមការជំនុំជម្រះនៃការចូលរួមរបស់សហគមន៍ខ្មែរ-ឥស្លាម មកពីបណ្តាខេត្តផ្សេងៗ ដូចជាខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តតាកែវ និងខេត្តកំពត ។ នៅថ្ងៃអង្គារ អ្នកចូលរួមប្រមាណជា ៥០០នាក់ ប្រហែលជា ២០០នាក់ មកពីស្រុកដងទុង និងស្រុកឈូក ខេត្តកំពត និងប្រមាណជា ២០០នាក់ទៀត មកពីស្រុកកោះធំ ខេត្តកណ្តាល ។ នៅថ្ងៃពុធ ប្រជាជនចំនួន ៤០០នាក់ មកពីខេត្តក្រចេះ និង ៦០នាក់ទៀត មកពីខេត្តកំពង់ឆ្នាំង ។ នៅថ្ងៃព្រហស្បតិ៍ មានក្រុមនិស្សិតចំនួន ២០០នាក់ មកពីសមាគមយុវជនខ្មែរ ប្រចាំខេត្តកណ្តាល (វិទ្យាល័យចំនួន ៤) និងប្រជាជនចំនួន ២០០នាក់ មកពីស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ចូលរួមសវនាការ ។

***បញ្ហាចោទនៅតុលាការ :*** ជាថ្មីម្តងទៀត បញ្ហាចោទនៅតុលាការបានកើតមានឡើង ជាពិសេស កន្លែងអង្គុយសម្រាប់អ្នកចូលរួមសវនាការ គឺមិនគ្រប់គ្រាន់ ។ ក្រុមអ្នកឃ្លាំមើលតុលាការសូមជម្រុញតុលាការរៀបចំបញ្ហានេះឱ្យបានសមស្របតាមលទ្ធភាព ឬកម្រិតចំនួនអ្នកចូលរួម ដែលត្រូវអញ្ជើញ ។

***បញ្ហាបច្ចេកទេស :*** កិច្ចដំណើរការនីតិវិធីសវនាការនាសប្តាហ៍នេះ ត្រូវរអាក់រអួលដោយប្រព័ន្ធបច្ចេកទេសសម្លេង ។ គួរកត់សម្គាល់ កិច្ចដំណើរការនីតិវិធី នៅថ្ងៃព្រហស្បតិ៍ ត្រូវបញ្ឈប់ភ្លាមៗ បន្ទាប់ពីចំណាយពេល ២០នាទី ជួសជុលបញ្ហាប្រព័ន្ធសម្លេងនោះ ។

***ការគ្រប់គ្រងពេលវេលា :*** កិច្ចដំណើរការនីតិវិធីសវនាការនាសប្តាហ៍នេះ បានប្រព្រឹត្តទៅយ៉ាងរលូនតាមកម្មវិធី ក្រៅពីបញ្ហាបច្ចេកទេស *(សូមមើលផ្នែកខាងលើ)* ។ អង្គជំនុំជម្រះបានខិតខំប្រឹងប្រែងធានាឱ្យសវនាការឆាប់រហ័ស ។ នៅរសៀលថ្ងៃពុធ ពុំមានការសម្រាក ព្រោះអង្គជំនុំជម្រះត្រូវធានាឱ្យដំណើរការប្រព្រឹត្តទៅស្របតាមកាលវិភាគ ដូច្នេះការត្រៀមរៀបចំសម្រាប់ថ្ងៃបន្ទាប់ ការស្តាប់សក្ខីកម្មពីចំងាយតាមទូរទស្សន៍ **(Video-conference)** លើដើមបណ្តឹងរដ្ឋប្បវេណីលោក **អ៊ូ សាវិទ្ធ** ។ ដូចគ្នានេះ នៅរសៀលថ្ងៃព្រហស្បតិ៍ ក៏មិនមានការឈប់សម្រាកដែរ ព្រោះអនុញ្ញាតិឱ្យដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី **ជុំ នៅ** បញ្ចប់សេចក្តីថ្លែងខ្លួន ប៉ុន្តែការប៉ុនប៉ងនេះមិនបានជោគជ័យ ដោយបញ្ហាប្រព័ន្ធបច្ចេកទេសសម្លេង ដូច្នេះកិច្ចដំណើរការនីតិវិធីត្រូវលើកពេល ។

## តារាងគ្រប់គ្រងពេលវេលា

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | សម្រាក អាហារថ្ងៃត្រង់ | សម្រាក ពេលរសៀល | ម៉ោងបញ្ចប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ចន្ទ័ ១៧-០៨-០៩ | ០៩:០៥ | ១០:៣៥-១០:៥៥ | ១២:១០-១៣:៤០ | ១៤:៤០-១៥:០០ | ១៦:២០ | ៤ ម៉ ២៥ នាទី |
| អង្គារ ១៨-០៨-០៩ | ០៩:០៧ | ១០:៣០-១០:៥៥ | ១២:០០-១៣:៣៥ | ១៤:៤០-១៥:១០ | ១៦:៣៥ | ៤ ម៉ ៥៨ នាទី |
| ពុធ ១៩-០៨-០៩ | ០៩:០៥ | ១០:២៥-១០:៤៥ | ១១:៥៥-១៣:៣៣ | - | ១៥:៣៥ | ៤ ម៉ ៣២ នាទី |
| ព្រហស្បត្តិ៍ ២០-០៨-០៩ | ០៩:០៥ | ១០:៣២-១០:៥៨ | ១២:០៣-១៣:៣០ | - | ១៦:១៣ | ៥ ម៉ ១៥ នាទី |

ចំនួនម៉ោងជាមធ្យម : ៤ ម៉ ៤០ នាទី

ចំនួនម៉ោងសរុបនាសប្តាហ៏នេះ : ២២ ម៉ ៤០ នាទី

ចំនួនសរុប ម៉ោង ថ្ងៃ និង សប្តាហ៏ នៅសវនាការ : ២៧២ ម៉ ៤៤ នាទី នៃ ៦១ ថ្ងៃសវនាការ នៃសប្តាហ៏ទី ១៧

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** (“កម្មវិធី”) : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៏រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៏ប្រចាំសប្តាហ៏ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៏ប្រចាំសប្តាហ៏នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** : ប្រធានកម្មវិធីសង្កេតការណ៏តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- លោក **Florian Hansen** : អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** : ស្វីស
- កញ្ញា **Deepika Sharma** : សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** : មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សាវ៉ន** : បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** : ស្វីស
- កញ្ញា **Binxin Zhang** : ចិន
- លោក **Jaspreet Dosanjh** : សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៏នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៏នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/ ។